# ចំណេះចំណានខាងគោលលទ្ធិ ៖ ការវាយតម្លៃទី ១ —សៀវភៅណែនាំការសិក្សា

**នីហ្វៃទី១ ៣:៧ ទៅដល់ ម៉ូសាយ ១៨:៨–១០**

## ទន្ទេញសេចក្តីយោង និងឃ្លាបទគម្ពីរគន្លឹះ

ចាប់ផ្តើមស្គាល់វគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិ និងឃ្លាបទគម្ពីរគន្លឹះ ។ អ្នកប្រហែលជាចង់ទាញយក និងប្រើកម្មវិធីឧបករណ៍ចល័តចំណេះចំណានខាងគោលលទ្ធិ ដើម្បីជួយអ្នកឲ្យរំឭកឡើងវិញ ។

| សេចក្តីយោងបទគម្ពីរ | ឃ្លាបទគម្ពីរគន្លឹះ |
|---|---|
| នីហ្វៃទី១ ៣:៧ | « ខ្ញុំនឹងទៅ ហើយធ្វើនូវអ្វីៗដែលព្រះអម្ចាស់ទ្រង់បានបញ្ជា » ។ |
| នីហ្វៃទី២ ២:២៥ | « លោកអ័ដាមបានធ្លាក់ខ្លួន ដើម្បីឲ្យមានមនុស្សលោក ហើយមានមនុស្សលោក ដើម្បីឲ្យគេអាចមានសេចក្តីអំណរ » ។ |
| នីហ្វៃទី២ ២:២៧ | « ពួកគេមានសិទ្ធិនឹងរើសយកឥស្សរភាព និងជីវិតដ៏នៅអស់កល្បជានិច្ច . . . ឬ . . . ការជាប់ឃុំឃាំង និងការស្លាប់ » ។ |
| នីហ្វៃទី២ ២៦:៣៣ | « មនុស្សទាំងអស់គ្នាគឺដូចគ្នានៅចំពោះព្រះ » ។ |
| នីហ្វៃទី២ ២៨:៣០ | ព្រះ « នឹងប្រទានដល់កូនចៅមនុស្សមួយបន្ទាត់ម្តងៗ មួយសិក្ខាបទម្តងៗ » ។ |
| នីហ្វៃទី២ ៣២:៣ | « សូមទទួលទាននូវព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ ដ្បិតមើលចុះ ព្រះបន្ទូលទាំងឡាយនៃព្រះគ្រីស្ទ នឹងប្រាប់ដល់អ្នកនូវគ្រប់អ្វីទាំងអស់ដែលអ្នកត្រូវធ្វើ » ។ |
| នីហ្វៃទី២ ៣២:៨–៩ | « អ្នករាល់គ្នាត្រូវតែអធិស្ឋានជានិច្ច » ។ |
| ម៉ូសាយ ២:១៧ | « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ។ |
| ម៉ូសាយ ២:៤១ | « អស់អ្នកណាដែលកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ . . . បានពរគ្រប់យ៉ាង » ។ |
| ម៉ូសាយ ៣:១៩ | « [ សម្រាត ] ភាពខាងសាច់ឈាមចេញហើយ [ ក្លាយ ] ទៅជាអ្នកបរិសុទ្ធវិញតាមរយៈដង្វាយធួននៃព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » ។ |
| ម៉ូសាយ ៤:៩ | « សូមជឿដល់ព្រះចុះ . . . សូមជឿថាទ្រង់មានគ្រប់ប្រាជ្ញា » ។ |
| ម៉ូសាយ ១៨:៨–១០ | ចូរ « ទទួលបុណ្យជ្រមុជទឹកដោយនូវព្រះនាមនៃព្រះអម្ចាស់ដើម្បីធ្វើជាសាក្សី . . . ថាអ្នករាល់គ្នាបានចូលក្នុងសេចក្តីសញ្ញាជាមួយនឹងទ្រង់ » ។ |

## អនុវត្តគោលលទ្ធិចំពោះស្ថានភាពជីវិតជាក់ស្តែង

- សូមប្រើវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិមួយ ឬច្រើន ដើម្បីជួយនរណាម្នាក់ដែលចង់បានការណែនាំ សម្រាប់ធ្វើការសម្រេចចិត្តសំខាន់ៗនៅក្នុងជីវិតរបស់គាត់ ឬនាង ។

- ជ្រើសរើសវគ្គបទគម្ពីរមួយ ឬច្រើន ដើម្បីជួយដល់នរណាម្នាក់ដែលមានអារម្មណ៍ថា ស្ថានភាពរបស់ពួកគេពិបាកធ្វើតាមព្រះបញ្ញត្តិទាំងឡាយរបស់ព្រះ ។

- សូមជ្រើសរើសវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិណាមួយ ហើយគិតអំពីស្ថានភាពមួយដែលសេចក្ដីពិតបានបង្រៀននៅក្នុងវគ្គបទគម្ពីរនោះអាចជួយដល់ក្មេងជំទង់ម្នាក់ក្នុងជីវិតរបស់គាត់ ។ បើសិនជាអាច សូមគិតអំពីស្ថានភាពពិតជាក់ស្ដែងដែលអ្នកបានដឹង ឬអ្នកបានជួបប្រទះដោយខ្លួនឯង ។

- សូមត្រៀមខ្លួនដើម្បីចែកចាយវគ្គបទគម្ពីរចំណេះចំណានខាងគោលលទ្ធិណាដែលមានឥទ្ធិពលលើអ្នកខ្លាំងបំផុត ។ តើវគ្គបទគម្ពីរនោះបង្រៀនអ្នកអ្វីខ្លះអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ?

## គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ

សូមរំឭកឡើងវិញនូវ កថាខណ្ឌទី ៥–១២ នៅក្នុងផ្នែក « ការទទួលបានចំណេះដឹងខាងវិញ្ញាណ » នៃ *ឯកសារគោលនៃចំណេះចំណានខាងគោលលទ្ធិ* ( ឆ្នាំ ២០២៣ ) ។ សូមពិចារណាគិតអំពីរបៀប ដែលអ្នកអាចប្រើប្រាស់គោលការណ៍នៃការទទួលបានចំណេះដឹងខាងវិញ្ញាណ ដើម្បីជួយដល់នរណាម្នាក់ឲ្យយកឈ្នះលើបញ្ហាប្រឈមមុខ ឬបញ្ហាកង្វល់ដែលគាត់កំពុងជួបប្រទះ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved. PD60013873_258_521-teacher_handout-1